ក្រសួងមហាផ្ទៃ

អគ្គនាយកដ្ឋានរដ្ឋបាល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១៧០៦ អរប

រដ្ឋបាលខេត្តកំពង់ធំ
ចូល លេខ: [illegible]
ថ្ងៃទី ១៧.៦.១៧ ម៉ោង
បញ្ជូនទៅ:

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី និងគ្រប់ខេត្ត**

**កម្មវត្ថុ:** ស្តីពីការផ្សព្វផ្សាយអាហារូបករណ៍ចំនួន១០២៨កន្លែង ក្នុងតំបន់អាស៊ីអាគ្នេយ៍ រួមមានថ្នាក់បណ្ឌិត ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បរិញ្ញាបត្រ ការអប់រំវិជ្ជាជីវៈ និងអាហារូបករណ៍ទូទៅ សម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ នៅតាមគ្រឹះស្ថានឧត្តមសិក្សាចំនួន១៨ នៃខេត្តគួយចូវ (Guizhou) របស់សាធារណរដ្ឋប្រជាមានិតចិន។

**យោង:** លិខិតលេខ៣៦អយក.សជណ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម** មេត្តាជ្រាបថា រដ្ឋាភិបាលចិនបានផ្តល់អាហារូបករណ៍ចំនួន១០២៨កន្លែង ក្នុងតំបន់អាស៊ីអាគ្នេយ៍ រួមមានប្រទេសកម្ពុជាផងដែរ ដែលអាហារូបករណ៍នេះរួមមាន ថ្នាក់បណ្ឌិតចំនួន២១កន្លែង ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន១១៥កន្លែង ថ្នាក់បរិញ្ញាបត្រចំនួន៤៣៩កន្លែង ការអប់រំវិជ្ជាជីវៈចំនួន២២០កន្លែង និងអាហារូបករណ៍ទូទៅចំនួន២៣៣កន្លែង សម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ ជូនដល់មន្ត្រីរាជការ និស្សិត សិស្ស និងបេក្ខជនកម្ពុជាដើម្បីមានឱកាសបានប្រឡងប្រជែងយកអាហារូបករណ៍ខាងលើ នៅតាមគ្រឹះស្ថានឧត្តមសិក្សាចំនួន១៨ នៃខេត្តគួយចូវ (Guizhou) របស់សាធារណរដ្ឋប្រជាមានិតចិន។ អាហារូបករណ៍នេះមានគោលបំណងដើម្បីបង្កើនចំណេះដឹងជូនដល់មន្ត្រីរាជការ និងបេក្ខជនកម្ពុជាលើការអប់រំវិជ្ជាជីវៈ ចំណេះដឹងទូទៅផ្សេងៗ និងដើម្បីពង្រឹងទំនាក់ទំនងអប់រំរវាងកម្ពុជា-ចិន។

ចំពោះមន្ត្រីរាជការ និងបេក្ខជនដែលមានបំណងចង់ចូលរួមប្រឡងប្រជែងយកអាហារូបករណ៍ខាងលើ សូមស្វែងរកព័ត៌មានលម្អិតផ្សេងៗតាមរយៈគេហទំព័រ http://www.seameo.org/SEAMEOWeb2/index.php?option=com_content&view=category&id=149&Itemid=427 ឬអាចទំនាក់ទំនងព័ត៌មានដោយផ្ទាល់ជាមួយ SEAMEO Secretariat តាមរយៈ secretariat@seameo.org។ អាហារូបករណ៍នេះនឹងផុតកំណត់ឈប់ទទួលពាក្យនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** មេត្តាជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

ប្រាក់ សំអឿន

សូមទំនាក់ទំនង:
- លោក ងួន គឹមសេង
- ទូរស័ព្ទលេខ: ០១១ ៣២២ ២២៧

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

លេខ : ១៨៤ ៧០.ររប

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** : ស្តីពីការផ្សព្វផ្សាយ ការប្រឡងជ្រើសរើសអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រចំនួន១០កន្លែង របស់សាកលវិទ្យាល័យ តាលី (DALI) សម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ នៅសាធារណរដ្ឋប្រជាមានិតចិន។

**យោង** : លិខិតលេខ៣៣អយក.សជណ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តម** មេត្តាជ្រាបថា សាកលវិទ្យាល័យ តាលី (DALI) បានផ្តល់អាហារូបករណ៍ថ្នាក់បរិញ្ញាបត្រចំនួន១០កន្លែង សម្រាប់ឆ្នាំសិក្សា ២០១៧-២០១៨ ជូនដល់មន្ត្រីរាជការ និស្សិត សិស្ស និងបេក្ខជនកម្ពុជា ដើម្បីបន្តការសិក្សានៅសាធារណរដ្ឋប្រជាមានិតចិន។ អាហារូបករណ៍នេះមានគោលបំណងបង្កើនចំណេះដឹងក្នុងជំនាញផ្សេងៗជូនសាធារណជនកម្ពុជា និងដើម្បីពង្រឹងទំនាក់ទំនងអប់រំរវាងកម្ពុជា-ចិន។ ចំពោះការចំណាយលើថ្លៃសំបុត្រយន្តហោះទៅ-មក ជាបន្ទុករបស់សាមីជន រីឯការចំណាយផ្សេងៗ លើការសិក្សា ការស្នាក់នៅ និងប្រាក់អាហារូបករណ៍ប្រចាំខែ (៤០០យ័ន) ជាបន្ទុករបស់សាកលវិទ្យាល័យ តាលី (DALI)។

សម្រាប់ព័ត៌មានលម្អិត និងលក្ខខណ្ឌជ្រើសរើសផ្សេងៗមានដូចខាងក្រោម ៖

I. **លក្ខណសម្បត្តិដើម្បីដាក់ពាក្យសុំអាហារូបករណ៍**

- មានសញ្ជាតិខ្មែរ
- មានអាយុមិនលើសពី២៥ឆ្នាំ
- មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
- មានសុខភាពល្អទាំងកាយសម្បទា និងសតិបញ្ញា

II. **សំណុំឯកសារត្រូវបំពេញ និងភ្ជាប់មកជាមួយ**

- ពាក្យសុំអាហារូបករណ៍ ០១ច្បាប់ (មានគំរូ)
- ជីវប្រវត្តិសង្ខេប ០១ច្បាប់ (មានគំរូ)
- កិច្ចសន្យា ០១ច្បាប់ (មានគំរូ)
- រូបថត ៤x៦ (ទើបថតថ្មី ផ្ទៃពណ៌ស) ០២សន្លឹក (ភ្ជាប់មកជាមួយពាក្យសុំ)
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើថតចម្លង០១ច្បាប់ (សូមភ្ជាប់នូវច្បាប់ដើមមកជាមួយដើម្បីផ្ទៀងផ្ទាត់)
- សេចក្តីបញ្ជាក់ពីគ្រឹះស្ថានសិក្សាចំពោះនិស្សិតដែលកំពុងសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា
- វិញ្ញាបនបត្រពិនិត្យកាយសម្បទា និងជម្ងឺអេដស៍ (០២ច្បាប់) ក្រោយពេលបេក្ខជនប្រឡងជាប់

III. **វិញ្ញាសាប្រឡង**

- គណិតវិទ្យា រយៈពេល (១ម៉ោង៣០នាទី)
- ភាសាអង់គ្លេស រយៈពេល (១ម៉ោង៣០នាទី)

IV. **មុខវិជ្ជាសិក្សា**

ចំពោះមុខជំនាញសិក្សា បេក្ខជនអាចជ្រើសរើសបាននៅពេលដែលរៀនចប់វគ្គភាសាចិនជោគជ័យ។

V. **កាលបរិច្ឆេទប្រឡង និងទីកន្លែងទទួលពាក្យ**

ការស្នើសុំពាក្យប្រឡង និងការទទួលពាក្យប្រឡងនឹងចាប់ផ្តើមពីថ្ងៃផ្សាយដំណឹងនេះតទៅរហូតដល់ថ្ងៃទី១៩ ខែកក្កដា **ឆ្នាំ២០១៧** ម៉ោង១៦:០០ល្ងាចនៅការិយាល័យអាហារូបករណ៍ និងកម្មវិធីសិក្សា នៃនាយកដ្ឋានទំនាក់ទំនងវប្បធម៌ និងអាហារូបករណ៍ ដែលមានអាសយដ្ឋាន អគារលេខ២៣ ផ្លូវ៣៦០ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន (ខាងកើតស្ថានីយ៍ទូរទស្សន៍អប្សរាចម្ងាយ៥០ម៉ែត្រ)។ ចំពោះកាលបរិច្ឆេទនៃការប្រឡង នឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែកក្កដា **ឆ្នាំ២០១៧** ដែលមណ្ឌលប្រឡងនឹងធ្វើការជម្រាបជូននៅពេលក្រោយ។ ចំពោះការចំណាយលើថ្លៃសំបុត្រយន្តហោះទៅ-មកជាបន្ទុករបស់សាមីជន រីឯការចំណាយផ្សេងៗលើការសិក្សា ការស្នាក់នៅ និងប្រាក់អាហារូបករណ៍ប្រចាំខែ (៤០០យ័ន) ជាបន្ទុករបស់សាកលវិទ្យាល័យ តាលី (DALI)។

ក្រោយពេលចេញលទ្ធផលប្រឡង ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជានឹងជ្រើសរើសបេក្ខជនដែលមានពិន្ទុខ្ពស់ចំនួន១០រូប ដើម្បីបញ្ជូនទៅសិក្សានៅសាកលវិទ្យាល័យ តាលី (DALI) នាខែកញ្ញា **ឆ្នាំ២០១៧**។

ចំពោះព័ត៌មានលម្អិតបន្ថែមដែលទាក់ទងនឹងអាហារូបករណ៍នេះ អាចសាកសួរដោយផ្ទាល់នៅការិយាល័យអាហារូបករណ៍ និងកម្មសិក្សាតាមអាសយដ្ឋានខាងលើ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** មេត្តាជ្រាប និងចាត់ចែងផ្សព្វផ្សាយដល់មន្ត្រីរាជការក្រោមឱវាទឱ្យបានទូលំទូលាយតាមការគួរ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**អគ្គនាយក**

ស៊ូ សុខខេង

**<u>សូមទំនាក់ទំនង៖</u>**

- លោក ងួន គឹមសេង
- ទូរស័ព្ទលេខ: ០១១ ៣២២ ២២៧